មន្ទីរពេទ្យ កាល់ម៉ែត
HOPITAL Calmette

ករុណា ការប្តេជ្ញា ឧត្តមភាព ប្រសិទ្ធភាព ទំនើបកម្ម

# ព្រឹត្តិបត្រសុខភាព មន្ទីរពេទ្យ កាល់ម៉ែត

## Calmette's Newsletter N° 01

ខែ មករា ២០១៧ - មីនា ២០១៧

ព្រឹត្តិបត្រលេខ ១




រៀបចំដោយ

គណៈកម្មការទស្សនាវដ្តីនៃមន្ទីរពេទ្យកាល់ម៉ែត

# ទំព័រផ្សេងៗ

ខែ មករា ២០១៧ - មិនា ២០១៧ ទស្សនាវដ្តីលេខ ១

# មាតិកា


១ **ដំណើរទស្សនកិច្ចឯកឧត្តមប្រធានាធិបតី** និងគណៈប្រតិភូនៃសាធារណរដ្ឋសិង្ហបុរីនៅមន្ទីរពេទ្យកាល់ម៉ែត!

២ **សិក្ខាសាលាស្តីអំពី** “ប្រព័ន្ធគ្រប់គ្រង ផ្នែកសម្ភព និងរោគស្ត្រី”

៣ **ជំងឺស្ទះសរសៃឈាមបេះដូង!** (HEART ATTACK)

៤ ទារកកើតពីម្តាយដែលមាន **ជំងឺទឹកនោមផ្អែម**!

៥ **ហេតុអ្វីចាំបាច់ត្រូវបំបៅកូនដោយទឹកដោះម្តាយ?**

៦ **ដំណឹងល្អសម្រាប់ស្ត្រីគ្រប់រូប**

៧ សូមអរកុណដោយបានជួយសង្គ្រោះជីវិតខ្ញុំតាមរយៈការផ្តល់**ឈាម**!

៨ គួរស្វែងយល់អំពី **ជំងឺហ្ស៊ីកា** ទាំងអស់គ្នា!

៩ **លាហើយរនេះរុញ!**







“ម៉ាស៊ីនស្កេន MRI”

facebook.com/calmette.gov.kh hospital@calmette.gov.kh www.calmette.gov.kh









# ដំណើរទស្សនកិច្ចឯកឧត្តមប្រធានាធិបតី

## និងគណៈប្រតិភូនៃសាធារណរដ្ឋសិង្ហបុរីនៅមន្ទីរពេទ្យកាល់ម៉ែត!

ក្នុងដំណើរទស្សនកិច្ចនាថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ នេះប្រព្រឹត្តទៅដោយមានភ្ជាប់ពិធីប្រគល់-ទទួល កម្មវិធី បណ្តុះបណ្តាលជំនាញសង្គ្រោះដោយគ្រោះថ្នាក់ប៉ះទង្គិចរវាងមន្ទីរពេទ្យកាល់ម៉ែត និងមន្ទីរពេទ្យតាន់តុកសេង ក្រោម អធិបតីភាព ដ៏ខ្ពង់ខ្ពស់នៃឯកឧត្តមបណ្ឌិត តូនី តាន់ កេង យាំ ប្រធានាធិបតី និងលោកជំទាវ នៃសាធារណរដ្ឋសិង្ហបុរី អមដោយឯកឧត្តម រដ្ឋមន្ត្រីក្រសួងសុខាភិបាលនៃប្រទេសទាំងពីរ ព្រមទាំងមានការបង្ហាញពីសកម្មភាពនៃការបណ្តុះបណ្តាលដែលជាលទ្ធផល នៃកិច្ចសហប្រតិបត្តិការរវាងមន្ទីរពេទ្យកាល់ម៉ែតនៃព្រះរាជាណាចក្រកម្ពុជា និងមន្ទីរពេទ្យតាន់តុកសេងនៃសាធារណរដ្ឋសិង្ហបុរី។







# សិក្ខាសាលាស្តីអំពី

## “ប្រព័ន្ធគ្រប់គ្រង ផ្នែកសម្ភព និងរោគស្ត្រី”

មន្ទីរពេទ្យកាល់ម៉ែត បានប្រារព្ធធ្វើសិក្ខាសាលាមួយដែលបានសហការរៀបចំឡើងជាមួយ ក្រុមសាស្ត្រាចារ្យ វេជ្ជបណ្ឌិតនៃសាកល វិទ្យាល័យ Nagoya ប្រទេសជប៉ុនក្រោម ប្រធានបទ “ប្រព័ន្ធគ្រប់គ្រង ផ្នែកសម្ភព និង រោគស្ត្រី” ។







សិក្ខាសាលានេះ បានប្រព្រឹត្តទៅ នៅថ្ងៃច័ន្ទ ទី២៩ ដល់ថ្ងៃអង្គារ ទី ៣០ ខែសីហា ឆ្នាំ ២០១៦ ដោយមានខ្លឹមសារផ្តោតសំខាន់លើការបណ្តុះបណ្តាលពី ប្រព័ន្ធគ្រប់គ្រងផ្នែកសម្ភព និងរោគស្ត្រី ការថែទាំសម្រាប់ស្ត្រី មានផ្ទៃពោះ ចាប់តាំងពីពេលមុនបង្កកំណើត និងក្រោយ ពេលប្រសូតបុត្រ បន្តតាមមើល ថែទាំពីការលូតលាស់របស់ ទារករហូតដល់ធំពេញវ័យ។ ខ្លឹមសារមួយសំខាន់ទៀតនោះ គឺ ការព្យាបាលជំងឺមហារីករោគស្ត្រី ដែលជាបទពិសោធន៍មួយ ថ្មីបន្ថែមទៀតសម្រាប់មន្ទីរពេទ្យ និងក្រសួងសុខាភិបាល នៃប្រទេសទាំងពីរ កម្ពុជា-ជប៉ុន ពិសេសជាអត្ថប្រយោជន៍ ដ៏ធំធេង សម្រាប់អ្នកជំងឺដែលមកទទួលយកសេវាថែទាំ ព្យាបាលទាក់ទងនឹងជំនាញនេះ។











# ជំងឺស្ទះសរសៃឈាមបេះដូង! (HEART ATTACK)

១) អ្វីជាជំងឺស្ទះសរសៃឈាមបេះដូង?

- គឺជាការខូច ឬស្លាកសាច់ដុំបេះដូងស្រួចស្រាវបណ្ដាលមកពីសរសៃឈាមដែលទៅចិញ្ចឹមបេះដូង (Coronary artery)។
- ជាជំងឺដែលមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់អាយុជីវិត, ត្រូវការការព្យាបាលពិសេស និងបន្ទាន់ (Absolute medical emergency) ដើម្បីកាត់បន្ថយអត្រាមរណភាព។

២) មូលហេតុ៖

ភាគច្រើន (លើសពី៩០%) បណ្ដាលមកពីការកកជាតិខ្លាញ់តាមសរសៃឈាមបេះដូង(Atherosclerosis)។

៣) ក្រុមមនុស្សដែលប្រឈមមុខ៖

- វ័យចំណាស់ (ប្រុស >៤៥ឆ្នាំ, ស្រី >៥៥ឆ្នាំ)
- លើសទម្ងន់
- មានជំងឺលើសឈាម
- មានជំងឺលើសជាតិស្ករ/ទឹកនោមផ្អែម
- មានជំងឺលើសជាតិខ្លាញ់ (High cholesterol)
- ពិសាបារី
- ពិសាស្រាច្រើន
- ប្រវត្តិក្រុមគ្រួសារមានជំងឺស្ទះសរសៃឈាមបេះដូង។

៤) រោគសញ្ញា៖

- ឈឺទ្រូងផ្នែកខាងមុខខ្លាំងរយៈពេលយូរ (លើសពី៣០នាទី) ហើយអាចសាយភាយទៅ ក, ដើមដៃ, ស្មា, ឬថ្គាម
- សញ្ញារួមផ្សំ:
  • បែកញើស
  • ទ្បេះទ្បះ
  • ចង់ក្អួត ឬហត់។

៥) ផលវិបាក៖

- វិបត្តិ ចង្វាក់បេះដូងធ្ងន់ធ្ងរ (Arrhythmia)
- ខ្សោយបេះដូង ( Heart failure)
- ចុះសម្ពាធឈាមធ្ងន់ធ្ងរ (Shock)
- គាំងបេះដូង -ស្លាប់ (Sudden death)

៦) រោគវិនិច្ឆ័យ៖

- ការវាស់ចង្វាក់បេះដូង (EKG)
- ការពិនិត្យឈាម អង់ស៊ីមបេះដូង (Troponin)
- អេកូបេះដូង (Heart ultrasound)
- ការថតឆ្លុះសរសៃឈាមបេះដូង (Angiography)

៧) ការព្យាបាល៖

- ការឆ្លុះសរសៃឈាម និង ពង្រីកដោយរ៉ឺស័រ ជាជម្រើសដ៏ល្អ និងបច្ចេកវិទ្យាទំនើបចុងក្រោយគេបង្អស់ ចំពោះការព្យាបាល ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ (Angioplasty with stent)។
- ការព្យាបាលដោយថ្នាំឲ្យបានទៀងទាត់តាមវេជ្ជបញ្ជាត្រឹមត្រូវ។

៨) វិធីការពារ៖

- ហាត់ប្រាណឲ្យបានទៀងទាត់ ៣០នាទីក្នុង១ថ្ងៃ, ៥ថ្ងៃក្នុង១សប្ដាហ៍
- ឈប់ពិសារបារី
- កាត់បន្ថយគ្រឿងស្រវឹងឲ្យបានច្រើនបំផុត
- ជៀសវាងអាហារប្រៃហួសប្រមាណ
- កាត់បន្ថយអាហារសំបូរជាតិខ្លាញ់, សាច់
- កាត់បន្ថយស្ថានភាពតានតឹងអារម្មណ៍ (Stress)
- គ្រប់គ្រងសម្ពាធឈាមឲ្យបានល្អប្រសិនបើលើសឈាម
- គ្រប់គ្រងជាតិស្ករឲ្យបានត្រឹមត្រូវប្រសិនបើលើសជាតិស្ករ ទៅតាមបទបញ្ជារបស់គ្រូពេទ្យ
- រក្សាទម្ងន់ឲ្យបានសមស្រប កុំឲ្យលើសទម្ងន់
- ជួបពិគ្រោះជាមួយគ្រូពេទ្យឯកទេសឲ្យបានទៀងទាត់។

ដូច្នេះប្រសិនបើបងប្អូនប្រជាពលរដ្ឋមានអាការៈ និងរោគសញ្ញាដូចបានជម្រាបជូនខាងលើ សូមអញ្ជើញមកពិគ្រោះជាមួយគ្រូពេទ្យជំនាញឯកទេសបេះដូងនៅមន្ទីរពេទ្យកាល់ម៉ែត ដើម្បីស្វែងរករោគវិនិច្ឆ័យ និងការព្យាបាលជំងឺនេះឲ្យបានទាន់ពេលវេលា ដោយបច្ចេកវិទ្យាទំនើបប្រកបដោយប្រសិទ្ធភាពខ្ពស់៕

"ក្រុមគ្រូពេទ្យជំនាញឯកទេសបេះដូងនៃមន្ទីរពេទ្យកាល់ម៉ែតរង់ចាំស្វាគមន៍ រាល់ការពិគ្រោះយោបល់ និងផ្ដល់ជូននូវការព្យាបាលគ្រប់ករណីជំងឺ បេះដូង និងសរសៃឈាម"

# ទារកកើតពីម្តាយដែលមាន ជំងឺទឹកនោមផ្អែម!

ជំងឺទឹកនោមផ្អែមចំពោះស្ត្រីមានផ្ទៃពោះមានប្រហែល៣ % ចំពោះស្ត្រីមានផ្ទៃពោះទាំង អស់។ ការតេស្តរកជំងឺទឹកនោមផ្អែមអំឡុង ពេលមានផ្ទៃពោះគឺចាប់ផ្តើមនៅពេលស្ត្រីមានគភ៌ចន្លោះពី២៤-២៨សប្តាហ៍។ ទារកកើតពីម្តាយដែលមានជំងឺទឹកនោមផ្អែម ដោយសារម្តាយមានកម្រិតជាតិស្ករក្នុងឈាម ខ្ពស់ជាងធម្មតាអំឡុងពេលមានគភ៌។

ស្ត្រីដែលប្រឈមមុខនឹងកើតជំងឺទឹកនោមផ្អែមពេលមានផ្ទៃពោះ៖
- ប្រវត្តិគ្រួសារមានជំងឺទឹកនោមផ្អែម
- ស្ត្រីធាត់
- ស្ត្រីដែលមានផ្ទៃពោះនៅអាយុ៣៥ឆ្នាំឡើងទៅ

ក) ការធ្វើតេស្តរកជំងឺទឹកនោមផ្អែមចំពោះស្ត្រីមានផ្ទៃពោះ ៖

ការធ្វើតេស្តរកជំងឺទឹកនោមផ្អែមចំពោះស្ត្រីមានផ្ទៃពោះគឺពឹងផ្អែកលើលទ្ធផលជាតិស្ករដែលបូមពីសរសៃឈាមវ៉ែន ដែលមានកម្រិតជាតិស្ករ៖
- កម្រិតជាតិស្ករព្រហាមមុនអាហារ ស្មើឬលើសពី 92mg/dL
- កម្រិតជាតិស្ករមួយម៉ោង ក្រោយផឹកទឹកស្ករ75ក្រាម ស្មើ ឬលើសពី 180mg/dL
- កម្រិតជាតិស្ករពីរម៉ោង ក្រោយផឹកទឹកស្ករ75ក្រាម ស្មើ ឬលើសពី 153mg/dL

បញ្ជាក់៖ លទ្ធផលណាមួយក៏បាន ដែលបង្ហាញខាងលើ ចាត់ទុកថាមានទឹកនោមផ្អែម។

ម្តាយដែលជំងឺទឹកនោមផ្អែមមិនបានតាមដានផ្ទៃពោះបានល្អ ទារកអាចប្រឈមមុខនឹងការស្លាប់ក្នុងផ្ទៃ និងការមានភាពមិនធម្មតាក្នុងផ្ទៃម្តាយ។

ខ) ផលប៉ះពាល់ជំងឺទឹកនោមផ្អែម៖

១) ចំពោះម្តាយ
- ក្រឡាភ្លើង
- ជំងឺខូចតម្រងនោម
- និងគ្រោះថ្នាក់ផ្សេងៗទៀត
- ទឹកភ្លោះច្រើន
- ជំងឺលើសឈាម

២) ចំពោះគភ៌
- ទារកមានទម្ងន់ច្រើនខុសធម្មតា ឬទារកមានគីឡូតិចជាងអាយុ
- ទារកកើតមិនគ្រប់ខែ
- ទារកខ្សោយក្នុងផ្ទៃ
- ភាពមិនធម្មតាធ្ងន់ធ្ងរពីកំណើតទាក់ទងបេះដូងពីកំណើត ខួរក្បាល ប្រពន្ធ័រំលាយអាហារ និងសិរីរាង្គផ្សេងៗទៀត។

៣) ចំពោះទារកក្រោយសម្រាល
- កង្វះជាតិស្ករក្នុងឈាម(< 40mg/dl)ច្រើនកើតនៅ២ម៉ោងក្រោយកើត
- កង្វះជាតិកាល់ស្យូមក្នុងឈាម
- កង្វះជាតិម៉ាញ៉េស្យូមក្នុងឈាម
- ទារកមានវិបត្តិផ្លូវដង្ហើម(4%)ដែលអាចបណ្តាលមកពី៖
  - សួតមិនទាន់ទុំ ដែលបណ្តាលមកពីកង្វះសារធាតុSurfactant នៅក្នុងថង់សួត។







  - វិបត្តិផ្លូវដង្ហើមរយៈពេលខ្លី ដែលបណ្តាលមកពីសល់ទឹកក្នុងសួតក្រោយសម្រាលទាក់ទង នឹងការសម្រាលដោយការវះកាត់
  - ការរីកធំនៃសាច់ដុំបេះដូង
- ទារកដែលធំលើសពី៤គីឡូ អាចមានគ្រោះថ្នាក់ពេលសំរាល ចំពោះទារកដូចជា បាក់ឆ្អឹងដៃ(ឆ្អឹងដងកាំបិត) មិនអាចកម្រើកដៃបានដោយសារប៉ះពាល់សរសៃប្រសាទដៃ(Paralysie de plexus brachial )។

គ) ការផ្តាំផ្ញើ៖

ស្ត្រីមានផ្ទៃពោះដែលមានជំងឺទឹកនោមផ្អែមត្រូវការចាំបាច់មានការតាមដានផ្ទៃពោះឲ្យបានទៀងទាត់ ជាមួយគ្រូពេទ្យច្រើនផ្នែកចូលរួមដូចជា ផ្នែកសម្ភព ផ្នែកទារក-កុមារ និងផ្នែកជំងឺទឹកនោមផ្អែម ដើម្បីទទួលការព្យាបាលឲ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាព និងដើម្បីកាត់បន្ថយគ្រោះថ្នាក់មុនពេលសម្រាល ក្រោយពេលសម្រាល និងភាពមិនធម្មតាពីកំណើតរបស់ទារក។

អ្នកម្តាយគ្រប់រូបគួរតាមដានផ្ទៃពោះឲ្យបានត្រឹមត្រូវក្នុងអំឡុងពេលមានផ្ទៃពោះ ជាមួយក្រុមគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យកាល់ម៉ែត ព្រោះជំងឺទឹកនោមផ្អែមនៅពេលមានផ្ទៃពោះអាចរកឃើញនៅពេលដែលគាត់មកពិនិត្យផ្ទៃពោះ និងសម្រាលនៅកន្លែងដែលមានសុវត្ថិភាពដើម្បីកាត់បន្ថយផលវិបាកចំពោះម្តាយនិងទារក៕





# ហេតុអ្វីចាំបាច់ត្រូវបំបៅកូនដោយទឹកដោះម្តាយ ?

ក) សារសំខាន់នៃការបំបៅទឹកដោះម្តាយ៖

- ការបំបៅផ្ទាល់ដោយដោះម្តាយជួយបង្កើនភាពស្និទ្ធស្នាល ដោយមាន ការប៉ះផ្ទាល់ រវាងស្បែកកូន និងស្បែកម្តាយ ធ្វើឲ្យកូនមានភាពកក់ក្តៅ និង ជួយពង្រឹងសុខភាពផ្លូវចិត្ត របស់ទារក និងម្តាយ។
- ទឹកដោះម្តាយជាអាហារដែលស្រស់ និងថ្មីបំផុត ព្រមទាំងគ្មានមេរោគ (ចំពោះម្តាយសុខភាពល្អ) និងសមស្របបំផុត សម្រាប់ផ្គត់ផ្គង់ ចិញ្ចឹមទារកទើបនឹងកើតរហូតដល់អាយុ ៦ខែ។
- ទឹកដោះដំបូងរបស់ម្តាយ សំបូរទៅដោយ:
  - អង់ទីគ័រ (IgA) និងគ្រាប់ឈាមស រាប់លានសម្រាប់ ការពារមេរោគ។
  - សារធាតុរ៉ែ និងវីតាមីនជួយទ្រទ្រង់សរពាង្គកាយរបស់កូន ជួយទប់ស្កាត់ការបាត់បង់ជាតិទឹក និងការស្រកទម្ងន់របស់កូន។
  - ប្រូតេអ៊ីន និងខ្លាញ់ព្រមទាំងអូមេហ្គា៣ និងសារជាតិផ្សេងទៀតជួយបង្កើនការលូតលាស់កុមារ មេតាបូលីស ថ្លើម ខួរក្បាល និងភ្នែក។
  - ជួយឲ្យកោសិកាឆាប់លូតលាស់ រីកធំធាត់ មានភាពស៊ាំមានប្រព័ន្ធការពារប្រឆាំងមេរោគ ( រលាកក្រពះ រាគរូស រលាកផ្លូវដង្ហើម និងរោគផ្សេងៗ)។
  - ជួយកាត់បន្ថយការចំណាយថវិកា និងការចំណាយពេលវេលាចាប់ពីនាទីដំបូងនៃកំណើតកូន។

ខ) កត្តាមួយចំនួនដែលជួយជំរុញក្នុងការផលិតទឹកដោះ៖

តាមពិតធម្មជាតិមានការរៀបចំយ៉ាងត្រឹមត្រូវ តាំងពីការចាប់កំណើតក្នុងផ្ទៃរហូតដល់គ្រប់ខែ និងគ្រប់គ្រាន់សម្រាប់ទារកទើបនឹងកើត។ ការដាក់ឲ្យកូនបៅដោះដោយត្រឹមត្រូវនិងមានភាពញឹកញាប់ធ្វើអោយខួរក្បាលម្តាយបញ្ជារឲ្យមានការបញ្ចេញអ័រម៉ូន Ocytocine និង Prolactine ដែលជាអ័រម៉ូនសម្រាប់ឲ្យមានការបង្កើតទឹក ដោះ និងបញ្ចេញទឹកដោះព្រមទាំងកាត់បន្ថយការធ្លាក់ឈាមក្រោយសម្រាល។ ម្តាយមួយចំនួនតែងបារម្ភខ្លាចមិនមានទឹកដោះគ្រប់គ្រាន់សម្រាប់ចិញ្ចឹមកូនដូចនេះដើម្បីបង្កើនការផលិតទឹកដោះមានកត្តាមួយចំនួនដែលជួយជំរុញក្នុងការផលិតទឹកដោះដោយ ៖

- សំអាតដោះឲ្យបានស្អាត និងសម្រាកអោយបានគ្រប់គ្រាន់
- ពិសាទឹកឲ្យបានគ្រប់គ្រាន់ ឬយ៉ាងតិច ៣លីត្រក្នុង ១ថ្ងៃ
- ពិសាអាហារឲ្យបានគ្រប់គ្រាន់និងត្រឹមត្រូវ
- ដាក់កូនឲ្យបៅដោះឲ្យបានទៀងទាត់
- ម៉ាស្សាដោះរបស់អ្នក ដែលអាចឲ្យមានទឹកដោះ(ដោយមិនប្រើផលិតផល ឬប្រេង):



- ដាក់ម្រាមដៃពីររបស់អ្នក ធ្វើចលនាជារង្វង់មូលលើផ្ទៃដោះ ទាំងមូល
- អ្នកក៏អាចម៉ាស្សាដោយប្រើកណ្តាប់ដៃ បង្វិលកណ្តាប់ដៃពីផ្ទៃដោះទៅក្បាលដោះ

គ) របៀបរក្សាទឹកដោះទុកឲ្យកូនបៅ៖

- លាងដៃឲ្យស្អាត មុននិងច្របាច់យកទឹកដោះ ឬកាន់ឧបករណ៍ផ្ទុកទឹកដោះ
- ផ្ទុកទឹកដោះក្នុងកំប៉ុង ឬថង់ដែលបិទជិតគ្មានមេរោគ និងមិនត្រូវដាក់ក្រោមកំដៅថ្ងៃ
- ដាក់ថ្ងៃខែ ដែលបានច្របាច់ទឹកដោះនៅលើឧបករណ៍ផ្ទុកទឹកដោះ។

"សូមបំបៅដោះម្តាយដល់កូនលោកអ្នក ជាពិសេសទឹកដោះដំបូង ដើម្បីឲ្យពួកគេមានការលូតលាស់បានល្អ ទាំងរាងកាយ និង ខួរក្បាល"

អ្នកម្តាយគ្រប់រូបដែលបានសម្រាលនៅផ្នែកសម្ភពមន្ទីរពេទ្យកាល់ម៉ែត ត្រូវបានទទួលការណែនាំអំពីរបៀបបំបៅដោះកូន៕







# ដំណឹងល្អសម្រាប់ស្ត្រីគ្រប់រូប



មន្ទីរពេទ្យកាល់ម៉ែតបានបំពាក់នូវបច្ចេកវិទ្យាថ្មីក្នុងការបង្ការជំងឺមហារីកមាត់ស្បូនដោយការធ្វើតេស្តរកមេរោគ HPV ដែលជាមូលហេតុនៃជំងឺមហារីកមាត់ស្បូន ។ តេស្តថ្មីដែលមានឈ្មោះថា careHPV test នេះ ជាបច្ចេកវិទ្យាចុងក្រោយពីប្រទេសអាឡឺម៉ង់ មានសមត្ថភាពអាចកំណត់បាននូវមេរោគ HPV ប្រភេទកាចសាហាវទាំង ១៤ ប្រភេទដែលអាចបង្កជាជំងឺមហារីកមាត់ស្បូន ។ មន្ទីរពេទ្យកាល់ម៉ែតជាមន្ទីរពេទ្យដំបូងគេបំផុតនៅក្នុងតំបន់អាស៊ាន ដែលបាននាំយកនូវបច្ចេកវិទ្យាថ្មី តេស្ត careHPV នេះ ។ មន្ទីរពេទ្យនឹងដាក់ឲ្យដំណើរការនូវតេស្តថ្មីនេះ ចាប់ពីថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៧ តទៅ ។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងលេខទូរស័ព្ទ ០៨៥ ២២ ១២ ៩២ ៕











ជំងឺ

# គួរស្វែងយល់អំពី ហ្ស៊ីកា ទាំងអស់គ្នា!

"ហ្ស៊ីកា" ជាប្រភេទជំងឺឆ្លង ដែលបង្កដោយពពួកវីរុស Zika ហើយភ្នាក់ងារចម្លងជាប្រភេទសត្វមូសខ្លា ដែលដូចគ្នាទៅនឹងជំងឺគ្រុនឈាម។ មានការផ្ទុះឡើងជាថ្មីនៃជំងឺហ្ស៊ីកានេះ នៅក្នុងប្រទេសមួយចំនួននៅតំបន់អាស៊ាន ដូចជាប្រទេសម៉ាឡេស៊ី និងប្រទេសសិង្ហបុរី។

ក) រោគសញ្ញា៖

ភាគច្រើននៃអ្នកកើតជំងឺនេះ (ប្រហែល ៧០ទៅ ៨០%) ពុំមានស្តែងចេញជារោគសញ្ញាអ្វីទាំងអស់ប៉ុន្តែរោគសញ្ញាដែលអាចកើតមានដូចជា៖

- ក្តៅខ្លួន
- រោគសញ្ញាលើស្បែក (ដូចជាស្នាមក្រហមអុចលើស្បែក)
- ឈឺសាច់ដុំ និងសន្លាក់ដៃជើង
- ភ្នែកឡើងក្រហម (រលាក Conjonctive ភ្នែក)
- រោគសញ្ញាបន្ទាប់បន្សំ:
  - អស់កម្លាំង
  - ឈឺក្បាល
  - វិបត្តិផ្លូវរំលាយអាហារ (រាគ ក្អួត)

ខ) ការកំណត់រោគវិនិច្ឆ័យ៖

ចំពោះអ្នកជំងឺដែលមានអាការៈដូចបានរៀបរាប់ខាងលើ គួរអញ្ជើញមកធ្វើការពិគ្រោះជាមួយ គ្រូពេទ្យជំនាញនៃមន្ទីរ ពេទ្យកាល់ម៉ែត ដើម្បីអាចធ្វើរោគវិនិច្ឆ័យពិតប្រាកដនៃជំងឺនេះ ហើយការធ្វើរោគវិនិច្ឆ័យនោះ ត្រូវបានធ្វើឡើង ដោយការកំណត់រកមេរោគប្រភេទ Zika នេះនៅក្នុងឈាមអ្នកជំងឺ។

គ) ការវិវត្តន៍នៃជំងឺ៖

- អត្រាមរណៈនៃជំងឺនេះមានចំនួនទាបនៅឡើយ
- ភាគច្រើននៃជំងឺនេះ នឹងវិវត្តទៅរកភាពជាសះស្បើយពី ២ថ្ងៃ ទៅ ៧ថ្ងៃ
- យ៉ាងណាក៏ដោយ ជំងឺនេះអាចបង្កផលលំបាកបន្ទាប់ពី មានការឆ្លងដូចជាជំងឺទន់ដៃជើង ដែលបណ្តាលមកពីការប៉ះ ពាល់ប្រព័ន្ធប្រសាទ (Guillain-Barré)
- ចំពោះស្ត្រីមានផ្ទៃពោះអាចប្រឈមនឹងទារកស្លាប់ក្នុងផ្ទៃ ឬទារកកើតមកបាន តែសភាពក្បាលមិនប្រក្រតី ដែលភាគច្រើនកើតឡើងលើស្ត្រីមានផ្ទៃពោះក្នុងអំឡុងត្រីមាសទី១ និងទី២ នៃគត៌។

**(មានបន្ត)**



# សូមអរគុណដោយ
# បានជួយសង្គ្រោះជីវិត
# ខ្ញុំតាមរយៈការផ្តល់
# **ឈាម** !



**បរិច្ចាគឈាមពិតជាមានអារម្មណ៍ជ្រះថ្លា!**

**ឈាមរបស់អ្នក ជួយជីវិតខ្ញុំ!**

**ផ្តល់ឈាមគឺផ្តល់សេចក្តីសង្ឃឹម!**









# លាហើយរទេះរុញ!





ប្អូនស្រីទី អាយុ ២១ឆ្នាំ ដែលជាក្មេងស្រីកំសត់ ដោយ ធ្លាប់ពិការជើងទាំង២កម្រើកមិនបាន។ ពីដំបូងនៅខែមករា ឆ្នាំ២០១៦ ប្អូនស្រីចាប់ផ្តើមដឹងថាជើងទាំងពីរទន់ដោយ គ្មានមូលហេតុ បន្ទាប់មកអាការៈនៃជំងឺនេះ បានវិវត្តន៍ទៅរកស្ថានភាពកាន់តែធ្ងន់ធ្ងរទៅៗរហូតដល់មិនអាចដើរកម្រើកនិងមិនអាចបញ្ឆាជើងទាំងពីររបស់ខ្លួនបាន នៅក្នុងកំឡុងខែមេសា ឆ្នាំ ២០១៦។

នៅខែឧសភា ឆ្នាំ២០១៦ ប្អូនស្រីទីបានចូលមកពិគ្រោះជំងឺនៅមន្ទីរពេទ្យកាល់ម៉ែតដោយស្ថានភាពអង្គុយលើរទេះរុញជើងទាំងពីរមិនអាចកម្រើក និងបញ្ឆាបាន។ ក្រោយពី វេជ្ជបណ្ឌិតធ្វើការពិនិត្យ និងធ្វើរោគវិនិច្ឆ័យ ឃើញថាប្អូនស្រី មាន ដុំសរសៃឈាមសង្កត់លើខួរឆ្អឹងខ្នង។ វេជ្ជបណ្ឌិតបាន សម្រេចធ្វើការវះកាត់នៅថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១៦។

បន្ទាប់ពីធ្វើការវះកាត់រួច ប្អូនស្រីអាចកម្រើកជើងខ្លះៗ ១-២ខែក្រោយមកអាចដើរបាន ៧០%។ ឥឡូវស្រីទីអាចដើរបានធម្មតាវិញហើយ ព្រមទាំងរត់បានទៀតផង។ជាមួយជំហានដំណើរដ៏សមសួន មាំមួន និងស្វាហាប់ ទឹក មុខស្រីទីស្រស់ស្រាយដោយស្នាមញញឹមពោរពេញដោយក្តីសង្ឃឹមជាថ្មីរបស់ប្អូនស្រីក្នុងអនាគតដ៏ត្រចះត្រចង់ រំលេចនូវ អត្ថន័យ លាហើយរទេះរុញ! ក្រោមមោទនភាពនៃក្រុម វេជ្ជបណ្ឌិតជំនាញវះកាត់នៅមន្ទីរពេទ្យកាល់ម៉ែត ដែលទទួលជោគជ័យក្នុងការជួយព្យាបាលប្អូនស្រីបានសម្រេចដូចក្តីប្រាថ្នា៕



លេខ ៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០១១ ៤១ ៤០ ៦៥, ០៧៧ ៣៦ ១៧ ៥១, ០១៧ ៨៦ ៦៨ ៤៧
អ៊ីម៉ែល: hospital@calmette.gov.kh, វេបសាយ: www.calmette.gov.kh